# ព្រះរាជក្រឹត្យ

នស/រកត/១២១៨/១៣៣៣៧

## ស្តីពី

## ការកែសម្រួលព្រះរាជក្រឹត្យលេខ នស/រកត/១១១៣/១១៩០ ចុះថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០១៣ ស្តីពីការកែសម្រួលព្រះរាជក្រឹត្យលេខ នស/រកត/០៨០៧/៣៩៣ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០៧ ស្តីពី ការកែសម្រួលព្រះរាជក្រឹត្យលេខ នស/រកត/១២០២/៣៥៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០២ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី
សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ
ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា
ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៧០៤/០០១ ចុះថ្ងៃទី១៣ ខែកក្កដា ឆ្នាំ២០០៤ ដែលប្រកាសឱ្យប្រើច្បាប់ធម្មនុញ្ញបន្ថែម សំដៅធានានូវដំណើរការជាប្រក្រតីនៃស្ថាប័នជាតិ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២០២/៣៥៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០២ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១១១៣/១១៩០ ចុះថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០១៣ ស្តីពីការកែសម្រួលព្រះរាជក្រឹត្យលេខ នស/រកត/០៨០៧/៣៩៣ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០៧ ស្តីពីការកែសម្រួលព្រះរាជក្រឹត្យលេខ នស/រកត/១២០២/៣៥៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០២ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

**ត្រាស់បង្គាប់**

**មាត្រាមួយ.-**

ត្រូវបានកែសម្រួលមាត្រា២ នៃព្រះរាជក្រឹត្យលេខ នស/រកត/១១១៣/១១៩០ ចុះថ្ងៃទី៥ ខែវិច្ឆិកា ឆ្នាំ២០១៣ ស្តីពីការកែសម្រួលព្រះរាជក្រឹត្យលេខ នស/រកត/០៨០៧/៣៩៣ ចុះថ្ងៃទី៣០ ខែសីហា ឆ្នាំ២០០៧ ស្តីពីការកែសម្រួលព្រះរាជក្រឹត្យលេខ នស/រកត/១២០២/៣៥៣ ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០០២ ស្តីពីការបង្កើតឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ដែលមានខ្លឹមសារដូចខាងក្រោម÷

**មាត្រា២.-ថ្មី**

**ឧបស** មានសមាសភាព និងរចនាសម្ព័ន្ធចាត់តាំងដូចខាងក្រោម÷

- **ឧបស** មានសមាជិកតាមការចាំបាច់ ដែលត្រូវមានគុណសម្បត្តិ ចំណេះវិជ្ជា និងបទពិសោធន៍ការងារក្នុងវិស័យណាមួយនៃមុខជំនាញសំខាន់ៗ ដូចជា សេដ្ឋកិច្ច ហិរញ្ញវត្ថុ នីតិសាស្ត្រ រដ្ឋបាលសាធារណៈ ពាណិជ្ជកម្ម កសិកម្ម ការគ្រប់គ្រងធនធានធម្មជាតិ បរិស្ថាន ឧស្សាហកម្ម ឬ វិស្វកម្ម
- **ឧបស** ត្រូវបានដឹកនាំ និងគ្រប់គ្រងដោយប្រធាន និងមានអនុប្រធានមួយចំនួនជាជំនួយការតាមសេចក្តីត្រូវការចាំបាច់
- ប្រធាន និងអនុប្រធាន **ឧបស** អាចមានជំនួយការអមមួយចំនួនតាមតម្រូវការចាំបាច់ជាក់ស្តែង
- សមាជិក **ឧបស** នីមួយៗ អាចមានជំនួយការអមមិនលើសពីពីររូប ដែលត្រូវមានសមត្ថភាពខាងផ្នែកចំណេះដឹងយ៉ាងតិចចាប់ពីថ្នាក់បរិញ្ញាបត្រឡើង
- ប្រធាន **ឧបស** មានឋានៈស្មើឧបនាយករដ្ឋមន្ត្រី
- អនុប្រធាន **ឧបស** មានឋានៈស្មើទេសរដ្ឋមន្ត្រី
- សមាជិក **ឧបស** អាចមានឋានៈស្មើរដ្ឋមន្ត្រី ឬ រដ្ឋលេខាធិការ ឬ អនុរដ្ឋលេខាធិការ
- ជំនួយការអមប្រធាន **ឧបស** អាចមានឋានៈស្មើអនុរដ្ឋលេខាធិការ ឬ អគ្គនាយក ឬ អគ្គនាយករង ឬ ប្រធាននាយកដ្ឋាន
- ជំនួយការអមអនុប្រធាន និងសមាជិក **ឧបស** អាចមានឋានៈស្មើអគ្គនាយក ឬ អគ្គនាយករង ឬ ប្រធាននាយកដ្ឋាន។

ROYAUME DU CAMBODGE • LE MINISTRE DU PALAIS ROYAL

**មាត្រាពីរ.** -

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រាបី.** -

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជាត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ថ្ងៃ សៅរ៍ ៩រោច ខែកត្តិក ឆ្នាំច សំរឹទ្ធិស័ក ព.ស ២៥៦២

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី ០១ ខែ ធ្នូ ឆ្នាំ២០១៨

នរោត្តម សីហមុនី

នស.រកត.១២១៨.១៣៤៤

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានចម្លងត្រឹមត្រូវតាមច្បាប់ដើម

**ឧបនាយករដ្ឋមន្ត្រីប្រចាំការ**

**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

កិត្តិនីតិកោសលបណ្ឌិត **ប៊ិន ឈិន**